ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង
សំណុំរឿងរដ្ឋប្បវេណីលេខ ៩៥
ចុះថ្ងៃទី០៩ -០៩ -២០២០
សាលក្រមលេខ៖ ១១ «ឃ »
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកោះកុង**

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

- ដើមចោទឈ្មោះ [redacted] ម៉ុន ភេទប្រុស អាយុ៨៥ឆ្នាំ ជនជតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

លោកមេធាវី [redacted] អត្តលេខ:២០១៨T មានអាសយដ្ឋានទីតាំងអាគារ [redacted] និង លោកមេធាវី [redacted] អត្តលេខ:០៨៥ និងលោកមេធាវី [redacted] អត្តលេខ:២១៨០T ជាមេធាវីតំណាងអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ម៉ុន ។

- ចុងចម្លើយឈ្មោះ [redacted] សុផាន់ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

**កម្មវត្ថុបណ្តឹង**:ប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចទាមទារឱ្យចុងចម្លើយរុះរើផ្ទះចេញពីទីតាំងដី ស្ថិតនៅភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង ដោយមាន សលាកបត្រព័ត៌មានលេខ: ០៩៦០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ និងវិញ្ញាបនបត្រសម្គាល់ អចលនវត្ថុលេខ: ០៩០៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។

- ទាមទារឱ្យចុងចម្លើយបង់ថ្លៃខូចខាតពេលវេលា និងសំណងជម្ងឺចិត្តចំនួន $២០០០០ (ពីរម៉ឺនដុល្លារអាមេរិក)។

- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**អង្គហេតុនិងចំណុចវិវាទ**

១-**ការទាមទាររបស់ដើមចោទ**

ប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេច ទាមទារឲ្យចុងចម្លើយរុះរើផ្ទះចេញពីទីតាំងដី ស្ថិតនៅភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង ដោយមានសលាកបត្រព័ត៌មាន



Scanned with CamScanner

លេខៈ ០៩៦០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ និងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ០៩០៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។

២-សេចក្តីថ្លែងការណ៍របស់គាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក-សេចក្តីថ្លែងការណ៍របស់គាគីដើមចោទ

-ក្នុងរឿងនេះមេធាវីតំណាងដោយអាណត្តិឱ្យរបស់ដើមចោទធ្វើសេចក្តីថ្លែងការណ៍ថាៈ សុំរក្សាពាក្យបណ្តឹងចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ទុកដដែល ។

មេធាវីតំណាងអាណត្តបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីអំឡុងឆ្នាំ២០០៧ កូនក្តីខ្ញុំឈ្មោះ [redacted] ម៉ុន បានចុះកិច្ចសន្យាទិញលក់ដី ពីលោកជំទប់ឃុំត្រពាំងរូងឈ្មោះ ប៉ើង ខាត់ ទំហំទទឹង៧០ម៉ែត្រ បណ្តោយទល់មាត់ព្រែក ដោយបានធ្វើកិច្ចសន្យាប្រគល់និងទទួលប្រាក់ត្រឹមត្រូវ និងមានបោះបង្គោលសម្គាល់ព្រំ ព្រមទាំងបានដាំដើមឈើ១ចំនួននៅលើដីនោះ ។ ស្រាប់អំឡុងឆ្នាំ២០១១ ឈ្មោះ [redacted] សុផាន់ បានចូលមកកាន់កាប់បំផ្លិចបំផ្លាដំណាំ ដើមឈើ និងរបងស៊ីម៉ងចោល ព្រមទាំងរំលោភបំពានសាងសង់ផ្ទះថ្មប្រក់ស័ង្កសីរស់នៅលើដីរបស់កូនក្តីខ្ញុំ ហើយកូនក្តីខ្ញុំក៏បានប្រាប់ឲ្យឈ្មោះ [redacted] សុផាន រុះរើផ្ទះចេញពីទីតាំងដី ព្រោះដីនេះជាកម្មសិទ្ធិរបស់កូនក្តីខ្ញុំ តែឈ្មោះ [redacted] សុផាន់ នៅតែមិនព្រមចាកចេញពីដីនេះ ។

អំឡុងឆ្នាំ២០១២ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សុរិយាដី បានចុះវាស់វែង ចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដើម្បីរៀបចំប្លង់កម្មសិទ្ធិ ចែកជូនប្រជាពលរដ្ឋនៅភូមិទំនាប ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង ក្រុមនិស្សិតក៏បានវាស់វែង និងបែងចែកដីនោះមកឲ្យកូនក្តីខ្ញុំឈ្មោះ [redacted] ម៉ុន កាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ។ ក្រុមនិស្សិតក៏បានចេញសលាកបត្រពតិមានលេខៈ ០០៥៩២៣ ដែលមានលេខក្បាលដីលេខៈ០៩៦០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ មកឲ្យកូនក្តិខ្ញុំ ។

នាអំឡុងឆ្នាំ២០១៣ ចុងចម្លើយក៏បានសាងសង់ផ្ទះ និងដាំដំណាំហូបផ្លែឈើមួយចំនួន ព្រមទាំងបោះបង្គោលសម្គាល់ព្រំដី កូនក្តីខ្ញុំក៏បានប្តឹងអន្តរាគមន៍ទៅអាជ្ញាធរមូលដ្ឋានឃុំ តែចុងចម្លើយឈ្មោះ [redacted] សុផាន់ បានគេចវេសពុំព្រមធ្វើការដោះស្រាយ ។ រហូតដល់ឆ្នាំ២០១៨ កូនក្តីខ្ញុំទទួលបានវិញ្ញបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។

ហេតុដូច្នេះដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របតាមផ្លូវច្បាប់ កូនក្តីខ្ញុំបានរៀបចំពាក្យបណ្តឹង ដើម្បីសុំឲ្យតុលាការសម្រេចប្រគល់ដីខាងលើ មកឲ្យកូនក្តីកាន់កាប់ ប្រើប្រាស់ អាស្រ័យផល ដោយផ្អែកលើ វិញ្ញបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ និងទាមទារឲ្យចុងចម្លើយឈ្មោះ [redacted] សុផាន់រុះរើផ្ទះចេញពីលើដីរបស់ឈ្មោះ [redacted] ម៉ុន និងទាមទារសំណងជំងឺចិត្តចំនួន២០០០០(ពីរម៉ឺន)ដុល្លាអាមេរិច ។

ខ-សេចក្តីថ្លែងការណ៍របស់គាគីចុងចម្លើយ

ចុងចម្លើយអះអាងថាៈ ខ្ញុំបាទពុំបានរស់នៅលើដីរបស់ឈ្មោះ [redacted] ម៉ុនទេ ។ ដែលខ្ញុំរស់នៅសព្វថ្ងៃគឺជាដីដែលខ្ញុំបានកាប់ឆ្ការ ហើយបានដាំដំណាំជាមួយឪពុកម្តាយតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ ហើយ មិនបានដឹងថាឈ្មោះ [redacted] ម៉ុន បានទិញដីនេះ ពីនរណានោះទេ ។ ក្រោយពីបានសាងសង់ផ្ទះលើដីដែលបានកាប់ឆ្ការរួច

ហើយ ទើបខ្ញុំបានដឹងថាជាដីរបស់រដ្ឋ ។ ខ្ញុំបានដឹងថាឈ្មោះ ជឹម មុំន គាត់មានដីនៅជាប់ដីដែលខ្ញុំរស់នៅ ហើយមានប្លង់រឹង តែខ្ញុំមិនបានទៅបំពានដីរបស់ឈ្មោះ [redacted] មុំន ដែលមានប្លង់រឹងនោះទេ គឺខ្ញុំនៅតែនៅលើដីដែលខ្ញុំបានកាប់ឆ្ការ និងដាំដំណាំ តាំងពីឆ្នាំ១៩៩៩ មក ។

ខ្ញុំសូមអះអាងចំពោះមុខតុលាការថា ប្រសិនបើដីដែលខ្ញុំរស់នៅជាដីរដ្ឋ ហើយរដ្ឋចឹងដកហូតវិញពេលណាគឺខ្ញុំមិនបដិសេធទេ គឺព្រមប្រគល់ជូនរដ្ឋគ្រប់ពេល តែប្រសិនបើប្រគល់ទៅឲ្យឯកជននោះខ្ញុំមិនយល់ព្រម ទេ ។

<u>គ. ចម្លើយរបស់សាក្សី</u>

- សាក្សី ឈ្មោះ [redacted] ឡាយ ភេទស្រី ដែលមានតួនាទីជាមេឃុំត្រពាំងរូង បានជម្រាបជូនតុលាការថា៖ ឈ្មោះ [redacted] សុផាន់ ជាប្រជាពលរដ្ឋរស់នៅ[redacted] តែក្រោយ មក ឈ្មោះ [redacted] សុផាន់ បានមកសាងសង់ផ្ទះ និងរស់នៅ ក្នុងឆ្នាំ២០១៩ ស្ថិតនៅ[redacted] ជាដីចំណីព្រៃក ស្ថិតនៅចំណុចគល់ស្ពានព្រែកតាច ជាដីរបស់រដ្ឋ ។ ខ្ញុំសូមបញ្ជាក់ឈ្មោះ [redacted] សុផាន់ នេះ បានសាងសង់ផ្ទះនៅកន្ទុយដីរបស់ឈ្មោះ [redacted] មុ៉ន ដែលជាដីរបស់រដ្ឋ ពុំមែនសាងសង់ផ្ទះចូលទៅក្នុង ដីដែលមានប្លង់រឹងរបស់ឈ្មោះ [redacted] មុ៉ន ឡើយ ។ ឈ្មោះ [redacted] មុ៉ន គាត់យោងសលាកបត្រពតិមានដីរបស់គាត់ទល់ព្រែក ក្រោយមកបានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ឃើញថាឈ្មោះ [redacted] មុ៉ន បានដីទំហំ៦០២៣ម៉ែត្រក្រឡា ដោយកាត់ចំណីព្រែកមួយចំនួនមិនដឹងថាចំនួនប៉ុន្មាននោះទេ ។

-សាក្សី ឈ្មោះ [redacted] ឪ ភេទប្រុស មានតួនាទីជាមេភូមិដីទំនាប បានជម្រាបជូនតុលាការថា៖ ឈ្មោះ [redacted] សុផាន់ ជាប្រជាពលរដ្ឋរស់នៅភូមិដី[redacted] ហើយឈ្មោះ នេះបានចេញពីភូមិដីទំនាបតាំងពីឆ្នាំ២០១៣ មុនខ្ញុំឡើងជាមេភូមិដីទំនាប ។ ឈ្មោះ [redacted] សុផាន់ ពុំទាន់ផ្ទេរទីលំនៅ(ស្ថិតិគ្រួសារពីភូមិដីទំនាបនៅឡើយទេ) ។ ឈ្មោះ [redacted] សុផាន់ មកសាងសង់ផ្ទះនៅភូមិត្រពាំងរូង លើដីឈ្មោះ [redacted] មុ៉ន ក៏ខ្ញុំមិនបានដឹងដែរ ។

-សាក្សី ឈ្មោះ [redacted] ភឿន ភេទប្រុស មានតួនាទីជាមន្ត្រីនៃការិយាល័យភូមិបាល និងសុរិយោដីស្រុកកោះកុង ខេត្តកោះកុង បានជម្រាបជូនតុលាការថា៖ ឈ្មោះ [redacted] សុផាន់ បានមកសាងសង់ផ្ទះ នៅភូមិត្រពាំងរូង ស្ថិតនៅគល់ស្ពានផ្លូវទៅជ្រោយប្រស់នោះ គឺជាដីរបស់រដ្ឋ ពុំមែនសាងសង់ផ្ទះលើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ដែលមានទំហំ៦០២៣ម៉ែត្រក្រឡា របស់ឈ្មោះ ជឹម មុ៉ន នោះទេ ។

<u>៣-សេចក្តីថ្លែងការណ៍របស់គាគីនៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់</u>

<u>ក-សេចក្តីថ្លែងការណ៍របស់គាគីដើមចោទ</u>

មេធាវីតំណាងអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំរក្សានូវកម្មវត្ថុពាក្យបណ្តឹង និងសេចក្តីថ្លែងការណ៍ដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ។ មេធាវីតំណាងអាណត្តិបានលើកឡើងថាកូនក្តីបានទិញដីដែលមានការទទួលស្គាល់ដឹងលឺត្រឹមត្រូវ បានកាន់កាប់តាំងពីឆ្នាំ២០០៧ រហូតមក ។ ដីដែលកូនក្តីខ្លួនកាន់កាប់នេះត្រូវបាននិស្សិតចុះវាស់វែង និងមានសលាកបត្រ រហូតនៅឆ្នាំ២០១៨ បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:



Scanned with CamScanner

០៩៣០៨០៨-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។ រហូតដល់ឆ្នាំ២០១៣ ឈ្មោះ [redacted] សុផាន់ បានមកបំពានចូលកាន់កាប់ និងសាងសង់ផ្ទះលើដីរបស់ឈ្មោះ [redacted] ម៉ុន ។

អាស្រ័យហេតុនេះ សំណូមតុលាការមេត្តាចេញសាលាក្រមដូចការទាមទាររបស់កូនក្តីខ្ញុំបាទ និងទាមទារសំណងការខូចខាត និងពេលវេលាចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

<u>ខ-សេចក្តីថ្លែងការណ៍របស់ភាគីចុងចម្លើយ</u>

ចុងចម្លើយឈ្មោះ [redacted] សុផាន់ បានឆ្លើយថាខ្លួនសុំរក្សានូវចម្លើយដែលបានឆ្លើយក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដដែល ។ ខ្លួនសូមអះអាងបញ្ជាក់ជូនតុលាការថា ខ្លួនពិតជាពុំបានកាន់កាប់ ឬសាងសង់ផ្ទះលើដីរបស់ដើមចោទឡើយ ហើយដីដែលខ្លួនកំពុងរស់នៅ និងបានសាងសង់ផ្ទះនេះ គឺដីដែលខ្លួនបានកាប់ឆ្ការតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ ហើយបច្ចុប្បន្នខ្លួនទទួលស្គាល់ថា ដីដែលខ្លួនកំពុងរស់នៅគឺជាដីរបស់រដ្ឋ ។

<u>-ភស្តុតាងដែលភាគីបានដាក់ជូនតុលាការមាន:</u>

-សលាកបត្រព័ត៌មានលេខ: ០៩៦០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៩០៣០៨០៨-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨។

-សាលក្រមព្រហ្មទណ្ឌលេខ:២២៣(ក) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកោះកុង

<u>៤-ចំណុចវិវាទ:</u>តើចុងចម្លើយពិតជាបានកាន់កាប់និងសាងសង់ផ្ទះលើដី របស់ដើមចោទដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩០៣០៨០៨-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៨ មែនដែរឬទេ?

## <u>សំអាងហេតុ</u>

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី និងពិនិត្យភស្តុតាងក្នុងដំណាក់កាលនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ យល់ឃើញថា:

១-មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទឈ្មោះ [redacted] ម៉ុន បានធ្វើសេចក្តីថ្លែងការណ៍ដោយសុំរក្សាពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ទុកដដែល។

២-មេធាវីតំណាងអាណិត្តបានធ្វើសេចក្តីថ្លែងការណ៍ថាៈ កាលពីអំឡុងឆ្នាំ២០០៧ កូនក្តីខ្ញុំឈ្មោះ [redacted] ម៉ុន បានចុះកិច្ចសន្យាទិញលក់ដី ពីលោកជំទប់ឃុំត្រពាំងរូងឈ្មោះ [redacted] ខាត់ ទំហំទទឹង ៧០ម៉ែត្របណ្តោយទល់មាត់ព្រែក ដោយបានធ្វើកិច្ចសន្យាប្រគល់និងទទួលប្រាក់ត្រឹមត្រូវ និងមានបោះបង្គោលសម្គាល់ព្រំ ព្រមទាំងបានដាំដើមឈើ១ចំនួននៅលើដីនោះ ។ ស្រាប់អំឡុងឆ្នាំ២០១១ ឈ្មោះ [redacted] សុផាន់ បានចូលមកកាន់កាប់បំផ្លិចបំផ្លាដំណាំ ដើមឈើ និងរបងស៊ីម៉ងចោល ព្រមទាំងរំលោភបំពានសាងសង់ផ្ទះថ្មប្រក់ស័ង្កសីរស់នៅលើដីរបស់កូនក្តីខ្ញុំ ហើយកូនក្តីខ្ញុំក៏បានប្រាប់ឲ្យឈ្មោះ [redacted] សុផាន រុះរើផ្ទះចេញពីទីតាំងដី ព្រោះដីនេះជាកម្មសិទ្ធិរបស់កូនក្តីខ្ញុំ តែឈ្មោះ [redacted] សុផាន់ នៅតែមិនព្រមចាកចេញពីដីនេះ ។

អំឡុងឆ្នាំ២០១២ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សុរិយាដី បានចុះវាស់វែង ចុះ



Scanned with CamScanner

បញ្ញិដិក្ខិជាប្រព័ន្ធ ដើម្បីរៀបចំប្លង់កម្មសិទ្ធិ ចែកជូនប្រជាពលរដ្ឋនៅភូមិទំនាប ឃុំក្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង ក្រុមនិស្សិតក៏បានវាស់វែង និងបែងចែកដីនោះមកឲ្យកូនក្តីខ្ញុំឈ្មោះ [redacted] ម៉ុន កាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ។ ក្រុមនិស្សិតក៏បានចេញសលាកបត្រពត៌មានលេខ:០០៥៩២៣ ដែលមានលេខក្បាលដីលេខ:០៩៦០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ មកឲ្យកូនក្តីខ្ញុំ ។

នាអំឡុងឆ្នាំ២០១៣ ចុងចម្លើយក៏បានសាងសង់ផ្ទះ និងដាំដំណាំហូបផ្លែឈើមួយចំនួន ព្រមទាំងបោះបង្គោលសម្គាល់ព្រំដី កូនក្តីខ្ញុំក៏បានប្តឹងអន្តរាគមន៍ទៅអាជ្ញាធរមូលដ្ឋានឃុំ តែចុងចម្លើយឈ្មោះ [redacted] សុផាន់ បានគេចវេសពុំព្រមធ្វើការដោះស្រាយ ។ រហូតដល់ឆ្នាំ២០១៨ កូនក្តីខ្ញុំទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៨០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។

ហេតុដូច្នេះដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របតាមផ្លូវច្បាប់ កូនក្តីខ្ញុំបានរៀបចំពាក្យបណ្តឹង ដើម្បីសុំឲ្យតុលាការសម្រេចប្រគល់ដីខាងលើ មកឲ្យកូនក្តីកាន់កាប់ ប្រើប្រាស់ អាស្រ័យផល ដោយផ្អែកលើ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៨០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ និងទាមទារឲ្យចុងចម្លើយឈ្មោះ [redacted] សុផាន់រុះរើផ្ទះចេញពីលើដីរបស់ឈ្មោះ [redacted] ម៉ុន និងទាមទារសំណងជំងឺចិត្តចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិច ។ តាមរយៈសេចក្តីថ្លែងការណ៍នេះ តុលាការយល់ឃើញថាភាគីដើមចោទបានលើកឡើងអំពីប្រវត្តិនៃការកាន់កាប់ដីរបស់ខ្លួន តាំងមិនទាន់មិនទាន់ទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ រហូតទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៨០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ អាស្រ័យហេតុនេះ គប្បីតុលាការធ្វើការពិចារណាដោយផ្អែកលើភស្តុតាងដែលមានក្នុងសំណុំរឿង ថាតើចុងចម្លើយពិតជាបានបំពានលើដីជាកម្មសិទ្ធិរបស់ដើមចោទដែរឬទេ ។

២-ចុងចម្លើយអះអាងថា: ខ្ញុំបាទពុំបានរស់នៅលើដីរបស់ឈ្មោះ [redacted] ម៉ុនទេ ។ ដែលខ្ញុំរស់នៅសព្វថ្ងៃគឺជាដីដែលខ្ញុំបានកាប់ឆ្ការ ហើយបានដាំដំណាំជាមួយឪពុកម្តាយតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ ហើយ មិនបានដឹងថាឈ្មោះ [redacted] ម៉ុន បានទិញដីនេះ ពីនរណានោះទេ ។ ក្រោយពីបានសាងសង់ផ្ទះលើដីដែលបានកាប់ឆ្ការរួចហើយ ទើបខ្ញុំបានដឹងថាជាដីរបស់រដ្ឋ ។ ខ្ញុំបាទដឹងថាឈ្មោះ [redacted] ម៉ុន គាត់មានដីនៅជាប់ដីដែលខ្ញុំរស់នៅ ហើយមានប្លង់រឹង តែខ្ញុំមិនបានទៅបំពានដីរបស់ឈ្មោះ [redacted] ម៉ុន ដែលមានប្លង់រឹងនោះទេ គឺខ្ញុំនៅតែនៅលើដីដែលខ្ញុំបានកាប់ឆ្ការ និងដាំដំណាំ តាំងពីឆ្នាំ១៩៩៩ មក ។ ខ្ញុំសូមអះអាងចំពោះមុខតុលាការថា ប្រសិនបើដីដែលខ្ញុំរស់នៅជាដីរដ្ឋ ហើយរដ្ឋចឹងដកហូតវិញពេល ណាគឺខ្ញុំមិនបដិសេធទេ គឺព្រមប្រគល់ជូនរដ្ឋគ្រប់ពេល តែប្រសិនបើប្រគល់ទៅឲ្យឯកជននោះខ្ញុំមិនយល់ព្រមទេ ។ តុលាការយល់ឃើញចុងចម្លើយបានឆ្លើយបដិសេធចំពោះ ការទាមទាររបស់ដើមចោទ អាស្រ័យហេតុនេះ គប្បីតុលាការធ្វើការពិចារណាដោយផ្អែកលើភស្តុតាងនានា ដែលមានក្នុងសំណុំរឿង ថាតើការទាមទារដើមចោទ និងការបដិសេធរបស់ចុងចម្លើយ ពិតជាមានភាពសម ស្របដែលអាចឲ្យតុលាការធ្វើការពិចារណា ។

៣-ផ្អែកតាមចម្លើយសាក្សីដែលជាមន្ត្រីអាជ្ញាធរឃុំ និងមន្ត្រីជំនាញសុរិយោដីបានបង្ហាញថាដើមចោទឈ្មោះ [redacted] ម៉ុន ពិតជាមានដីដែលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៨០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ប្រាកដមែន ។ ប៉ុន្តែឈ្មោះ [redacted] សុផាន់ ដែលឈ្មោះ [redacted] ម៉ុន



Scanned with CamScanner

ប្តឹងទាមទារនេះ ពុំបានកាន់កាប់ ឬសាងសង់លើដីដែលជាចំណែកកម្មសិទ្ធរបស់ដើមចោទឡើយ ។ គឺឈ្មោះ តង់ សុផាន់ បានរស់នៅនិងសាងសង់ផ្ទះលើដីរបស់រដ្ឋ ។ តាមរយៈចម្លើយនេះបានបង្ហាញពិចម្លើយស្របគ្នារបស់ចុងចម្លើយឈ្មោះ [redacted] សុផាន់ ដែលបានឆ្លើយទទួលស្គាល់ថាខ្លួនរស់នៅលើដីរបស់រដ្ឋ ។

៤-ផ្អែកតាមភស្តុតាងដែលដើមចោទបានដាក់មកតុលាការពិនិត្យឃើញថា ដើមចោទពិតជាមានដីដែលជាកម្មសិទ្ធរបស់ខ្លួន ដូចមានក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៨ ប្រាកដមែន ។ ប៉ុន្តែដីដែលឈ្មោះ តង់ សុផាន់ កំពុងរស់នៅ និងបានសាងសង់ផ្ទះគឺជាដីរដ្ឋ(ចំណីព្រែក)ដែលពុំត្រូវបានចាត់ទុកជាដីរបស់បុគ្គលឯកជនណាឡើយ ។ អាស្រ័យហេតុនេះ ដីដែលដើមចោទទាមទារ និងសុំឲ្យរុះរើផ្ទះចេញពុំមែនជាដីកម្មសិទ្ធស្របតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៩៣០៤០៤-០៩៦០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ នោះឡើយ ហេតុដូចនេះហើយ មិនអាចទទួលស្គាល់ការទាមទាររបស់ដើមចោទនោះឡើយ គប្បីច្រានចោលការទាមទារ ។

៥-ផ្អែកតាមខ្លឹមសារនៃសាលាក្រមព្រហ្មទណ្ឌលេខ២២៣(ក)ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកោះកុង មានភាពសមស្របទៅនឹងការអះអាងរបស់អាជ្ញាធរមានសមត្ថកិច្ច និងចម្លើយរបស់ឈ្មោះ [redacted] សុផាន់ ដែលបង្ហាញថាដីដែលឈ្មោះ [redacted] សុផាន់ រស់នៅ និងសាងសង់ផ្ទះជាដីរបស់រដ្ឋ ពុំបានសាងសង់ចូលដីកម្មសិទ្ធរបស់ដើមចោទឡើយ ។ អាស្រ័យហេតុនេះ ការទាមទាររបស់ដើមចោទ ពុំមានលក្ខណ:សមស្របដែលអាចឲ្យតុលាការជឿជាក់ និងធ្វើការពិចារណាបានឡើយ គប្បីច្រានចោលការទាមទាររបស់ដើមចោទ ។

៦-ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលការទាមទាររបស់ដើមចោទ ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណ: នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងចុងចម្លើយ ។

ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃច័ន្ទ ៦កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កោះកុង, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

**ហត្ថលេខានិងត្រា៖ តាព សុតា**

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

កោះកុង, ថ្ងៃទី១៧ ខែឧសភាឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

កោះកុង, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

**ចៅក្រម**

[redacted]



Scanned with CamScanner